ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

លេខ :  ✓  មស.

## សារលិខិតថ្វាយព្រះពរ

**សូមក្រាបបង្គំទូលថ្វាយ**

**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**

**នៃព្រះរាជាណាចក្រកម្ពុជា**

**ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត**!

ក្នុងឱកាសដ៏មហានក្ខត្តឫក្ស នៃពិធីបុណ្យចូលឆ្នាំសកល ឆ្នាំ២០២២ ខាងមុខនេះ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា ជាថ្នាក់ដឹកនាំនិងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ សូមព្រះបរមរាជានុញ្ញាតក្រាបបង្គំទូលថ្វាយ **ព្រះករុណាជាអម្ចាស់** នូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតចំពោះព្រះរាជសកម្មភាពដ៏ឧត្តុង្គឧត្តម ថ្លៃថ្លា ប្រកបដោយទសពិធរាជធម៌ ដើម្បីជាតិមាតុភូមិ និងប្រជារាស្ត្រជាទីស្រឡាញ់របស់ព្រះអង្គ និងសូមលំឱនកាយអញ្ជលីប្រណមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ វត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក ប្រោះព្រំព្រះរាជសព្ទសាធុការពរ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរ ថ្វាយចំពោះ **ព្រះករុណាជាអម្ចាស់** សូមព្រះអង្គសមប្រកបដោយព្រះបរមសុខ ព្រះបញ្ញាញាណភ្លឺថ្លា ព្រះជន្មាយុយឺនយូរ ដើម្បីគង់ប្រថាប់ជាអគ្គមគ្គុទ្ទេសក៍ ដឹកនាំប្រទេសឆ្ពោះទៅកាន់វឌ្ឍនភាពនិងសុភមង្គលជាកិយ្យោភាព។

សូម **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ទ្រង់ព្រះមេត្តាទទួលនូវអភិវន្ទនកិច្ច និងព្រះសេយ្យភក្តីដ៏ស្មោះស្ម័គ្របំផុតពីទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា។ ៚

ថ្ងៃ ពុធ ៣ រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ២០២១

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ**

**រដ្ឋមន្ត្រី**

ព្រុំ សុខា

ផ្លូវវត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh